# គោលនយោបាយការការពាររបស់អង្គការថែរអន្តរជាតិ ៖ និយមន័យ

និយមន័យទាំងនេះត្រូវបានផ្តល់ជូនដើម្បីជួយដល់ការយល់ដឹង និងការអនុវត្តគោលនយោបាយនៃការពាររបស់អង្គការថែរអន្តរជាតិ និងក្រមសីលធម៌នៃការការពាររបស់អង្គការថែរអន្តរជាតិ។ និយមន័យនឹងត្រូវបានធ្វើបច្ចុប្បន្នភាពតាមតម្រូវការ ហើយជាកម្មសិទ្ធិរបស់ជនបង្គោលផ្នែក ការទប់ស្កាត់នៃការបៀតបៀន ការកេងប្រវ័ញ្ច និងការបំពានផ្លូវភេទ នៃអង្គការថែរអន្តរជាតិ។ សូមទំនាក់ទំនងជនបង្គោលផ្នែក ការទប់ស្កាត់នៃការបៀតបៀន ការកេងប្រវ័ញ្ច និងការបំពានផ្លូវភេទរបស់អ្នក ប្រសិនបើអ្នកមានចម្ងល់ ឬសំណួរណាមួយអំពីនិយមន័យទាំងនេះ។

## ការការពារ

វិធានការដែលយើងដាក់ គឺដើម្បីបង្ការ រាយការណ៍ និងឆ្លើយតបទៅនឹងគ្រោះថ្នាក់ ឬការបំពាន និងដើម្បីការពារសុខភាព សុខុមាលភាព និងសិទ្ធិមនុស្សរបស់បុគ្គលណាម្នាក់ដែលមានទំនាក់ទំនងនឹងអង្គការថែរ មិនថាជានិយោជិត អង្គការថែរ និងបុគ្គលិកពាក់ព័ន្ធ ដៃគូ អ្នកចូលរួមកម្មវិធី និងសហគមន៍នោះទេ។

## ការបៀតបៀនផ្លូវភេទ[1]

ការបៀតបៀនផ្លូវភេទ គឺជាការមិនស្វាគមន៍ទាក់ទងនឹងទំនោរផ្នែកផ្លូវភេទណាមួយរួមមាន ការប្រើប្រាស់ពាក្យសម្តី ការទាមទារទៅលើផ្លូវភេទដោយ ការបញ្ចេញឬបង្ហាញឱ្យឃើញ ការប៉ះពាល់ ការនិយាយលេងសើច កាយវិការ ឬការប្រាស្រ័យទាក់ទង ឬទង្វើដែលមានលក្ខណៈផ្លូវភេទណាមួយ ទោះបីទង្វើនោះធ្វើឡើងជា ពាក្យសំដី ជាលាយលក្ខណ៍អក្សរក្តី ឬរូបភាពក្តី ដោយបុគ្គលណាម្នាក់ ទៅកាន់បុគ្គលម្នាក់ផ្សេងទៀត។ ការបៀតបៀនផ្លូវភេទក៏រួមបញ្ចូលអាកប្បកិរិយាផ្សេងទៀតនៃលក្ខណៈផ្លូវភេទដែលអាចត្រូវបានរំពឹងទុក ឬត្រូវបានយល់ឃើញដោយសមហេតុផល ដើម្បីបង្កឱ្យមានការរំខាន ឬអាម៉ាស់ដល់បុគ្គលម្នាក់ទៀត នៅពេលដែលអាកប្បកិរិយាបែបនេះរំខានដល់ការងារ ត្រូវបានបង្កើតជាលក្ខខណ្ឌនៃការងារ ឬបង្កើតបរិយាកាសការងារដែលអវិជ្ជមាន ឬបំពាន។ ខណៈពេលដែល ការប្រព្រឹត្តទាំងនោះអាចមានទម្រង់ជាឧប្បត្តិហេតុដែលកើតឡើងតែម្តងផងដែរ។

[1]និយមន័យនៃ "ការបៀតបៀនផ្លូវភេទ" ពីព្រឹត្តិប័ត្ររបស់អគ្គលេខធិការនៃអង្គការសហប្រជាជាតិ៖ ការហាមឃាត់ការរើសអើង ការបៀតបៀន រួមទាំងការបៀតបៀនផ្លូវភេទ និងការបំពានសមត្ថកិច្ច (ST/SGB/2008/5)។

## ការកេងប្រវ័ញ្ចផ្លូវភេទ[2]

ការកេងប្រវ័ញ្ចផ្លូវភេទ គឺជាការរំលោភបំពានជាក់ស្តែង ឬការប៉ុនប៉ងរំលោភបំពានលើគោលជំហរនៃភាពងាយរងគ្រោះ ភាពខុសគ្នានៃអំណាច ឬទំនុកចិត្តខុសគ្នា ក្នុងគោលបំណងផ្លូវភេទ។

## ការបំពានផ្លូវភេទ

ការបំពានផ្លូវភេទ គឺជាការរំលោភបំពានរាងកាយជាក់ស្តែង ឬការគំរាមកំហែងរំលោភបំពានផ្លូវភេទណាមួយ ទោះបីជាដោយការប្រើកម្លាំង ឬក្រោមលក្ខខណ្ឌមិនស្មើភាព ឬដោយការបង្ខិតបង្ខំ។

## កុមារ[3]

កុមារ គឺជាបុគ្គលទាំងឡាយណាដែលស្ថិតក្រោមអាយុ ១៨ ឆ្នាំ ដោយមិនគិតពីការកំណត់និយមន័យរបស់ប្រទេសជាក់ស្តែងអំពីពេលវេលាដែលកុមារឈានដល់ភាពពេញវ័យ។

## មនុស្សពេញវ័យដែលងាយរងគ្រោះ

បុគ្គលណាម្នាក់ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅដែលៈ

- មិនអាចមើលថែខ្លួនឯង/ការពារខ្លួនពីគ្រោះថ្នាក់ ឬការកេងប្រវ័ញ្ច ឬ
- ដោយសារតែយេនឌ័រ សុខភាពផ្លូវចិត្តឬរាងកាយ ពិការភាព ជាតិសាសន៍ អត្តសញ្ញាណសាសនា ទំនោរផ្លូវភេទ ស្ថានភាពសេដ្ឋកិច្ចឬសង្គម ឬដោយសារគ្រោះមហន្តរាយនិងជម្លោះ ត្រូវបានចាត់ទុកថាមានហានិភ័យ
- ស្ថិតក្នុងស្ថានភាព ក្រោមបង្គាប់ ដែលធ្វើឱ្យជួបប្រទះកម្រិតអំណាចខុសគ្នា ហើយធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យនៃការបំពាន ការកេងប្រវ័ញ្ច និងការបំពានផ្លូវភេទ ការបំពានរូបរាងកាយ និងផ្លូវអារម្មណ៍ និងការមិនអើពើ។

**ការបំពានលើមនុស្សពេញវ័យ** (ពាក់ព័ន្ធនឹងចំណុចមួយ ឬច្រើនដូចខាងក្រោម)៖

### ក) ការបំពានផ្លូវអារម្មណ៍

ការបំពានផ្លូវអារម្មណ៍អាចកើតឡើងពីការប្រើពាក្យសំដី ឬធ្វើសកម្មភាពមិនសមរម្យចំពោះបុគ្គលម្នាក់។ ការបំពានផ្លូវអារម្មណ៍ជាការប៉ុនប៉ងក្នុងការបំផិតបំភ័យ គ្រប់គ្រង ឬផ្តាច់ខ្លួនបុគ្គលណាម្នាក់ដោយ

[2]និយមន័យនៃ "ការកេងប្រវ័ញ្ចផ្លូវភេទ" និង "ការបំពានផ្លូវភេទ" ពីព្រឹត្តិប័ត្ររបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ៖ វិធានការពិសេសសម្រាប់ការការពារពីការកេងប្រវ័ញ្ច និងបំពានផ្លូវភេទ (ST/SGB/2003/13)។

[3]និយមន័យកុមារពីគោលការណ៍ណែនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍អន្តរទីភ្នាក់ងារ (IASC) ដើម្បីអនុវត្តស្តង់ដារប្រតិបត្តិការអប្បបរមាសម្រាប់ការការពារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានដោយបុគ្គលិកអង្គការសហប្រជាជាតិ និងមិនមែនអង្គការសហប្រជាជាតិ ខែមីនា ឆ្នាំ២០១៣។

ការគំរាមកំហែង ឬការភ័យខ្លាច។ ការបំពានផ្លូវអារម្មណ៍អាចពាក់ព័ន្ធនឹងការប្រាប់បុគ្គលម្នាក់ដោយចេតនាថាពួកគេគ្មានតម្លៃ ធ្វើឱ្យគេអាម៉ាស់ និងការមិនឱ្យតម្លៃ ឬតបន្ថឹងការផ្លាស់ទីរបស់បុគ្គលម្នាក់ មិនផ្តល់ឱកាសដល់បុគ្គលម្នាក់ក្នុងការបញ្ចេញទស្សនៈរបស់ពួកគេ ការចំអកឱ្យបុគ្គលម្នាក់ និងអាកប្បកិរិយាបង្ខិតបង្ខំនិងគ្រប់គ្រង ឬការគំរាម កំហែងហែកកេរ្តិ៍។ សម្រាប់គោលបំណងនៃគោលនយោបាយការពារ អង្គការឃែរអន្តរជាតិនេះ ការបំពានផ្លូវអារម្មណ៍ត្រូវ បានកំណត់និយមន័យទាក់ទងនឹងការប្រព្រឹត្តមិនត្រឹមត្រូវ ចំពោះអ្នកចូលរួមកម្មវិធី និងសមាជិកសហគមន៍។ និយោជិតរបស់ អង្គការឃែរ និងបុគ្គលិកដែលពាក់ព័ន្ធត្រូវយោងទៅគោលនយោបាយធនធានមនុស្សរបស់ពួកគេ ប្រសិនបើពួកគេកំពុងជួបប្រទះការបំពានផ្លូវអារម្មណ៍ និង/ឬការធ្វើបាបដោយនិយោជិតរបស់ អង្គការឃែរ ឬបុគ្គលិកដែលពាក់ព័ន្ធ។

### ខ) ការមិនអើពើ

សម្រាប់គោលនយោបាយការពារសុវត្ថិភាពរបស់ អង្គការឃែរអន្តរជាតិ ការមិនអើពើ គឺនៅពេលដែលនិយោជិតរបស់ អង្គការឃែរ ឬបុគ្គលិកដែលពាក់ព័ន្ធមានកាតព្វកិច្ចតាមតួនាទីការងាររបស់ពួកគេបានខកខាន ក្នុងការបំពេញតាមតម្រូវការមូលដ្ឋាន និងចាំបាច់របស់អ្នកចូលរួមកម្មវិធី ឬសមាជិកសហគមន៍ ដែលពួកគេអាចធ្វើបាន។ នេះអាចជាចេតនា ឬការខកខានក្នុងការយល់ពីតម្រូវការ។ ការមិនអើពើ រួមបញ្ចូលទាំងការមិនព្រមឱ្យដោយចេតនាដូចជា ថ្នាំ អាហារ ទឹក ជម្រក។

### គ) ការបំពានលើរូបរាងកាយ

ការប្រើប្រាស់កម្លាំងដោយចេតនា ឬសកម្មភាពដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់រាងកាយ ឬរបួស រួមទាំងគ្រោះថ្នាក់ដល់រាងកាយដែលអាចនឹងកើតមាន។ ឧទាហរណ៍គឺការរុញ ការដាល់ ការទះ ការទាត់ ការខាំ ការខាកស្តោះទៅលើនរណាម្នាក់ ការដុត ការរារាំង ឬការវាយនរណាម្នាក់ដោយវត្ថុ។ ការបំពានលើរូបរាងកាយ អាចជាឧប្បត្តិហេតុកើតឡើងតែម្តង ឬឧប្បត្តិហេតុដដែលៗ។

### ឃ) ការបំពានផ្នែកហិរញ្ញវត្ថុ និងសម្ភារៈ

ការបំពានប្រភេទនេះរួមបញ្ចូលទាំងការគ្រប់គ្រងប្រាក់ ឬធនធានតាមរយៈការលួច ការបោកបញ្ឆោត ការបង្ខិតបង្ខំ ឬសកម្មភាពមិនសមរម្យផ្សេងទៀត។ ការបំពានប្រភេទនេះអាចលាតសន្ធឹងវិសាលភាពដល់បណ្តាំមត៌ក មត៌ក ឬទ្រព្យសម្បត្តិមានតម្លៃ (ឧទាហរណ៍ គ្រឿងអលង្ការ)។ ការបំពានផ្នែក ហិរញ្ញវត្ថុ និងសម្ភារៈពេលខ្លះត្រូវបានផ្សារភ្ជាប់ទៅនឹងប្រភេទនៃការបំពានផ្សេងទៀត រួមមានការគ្រប់គ្រងដោយបង្ខិតបង្ខំ ការបំពានលើរូបរាងកាយ ឬផ្លូវភេទ។

## ការគ្រប់គ្រងដោយបង្ខិតបង្ខំ

ការគ្រប់គ្រងដោយការបង្ខិតបង្ខំ គឺជាទង្វើ ឬលំនាំនៃសកម្មភាពនៃការប្រើអំពើហិង្សា ការគំរាមកំហែង

ការធ្វើឱ្យអាម៉ាស់ ឬការបំភិតបំភ័យ ឬការបំពានផ្សេងទៀតដោយបុគ្គលម្នាក់ដែលធ្លាប់បង្កគ្រោះថ្នាក់ ដាក់ទណ្ឌកម្ម ឬធ្វើឱ្យជនរងគ្រោះ/អ្នករស់រានមានជីវិតរបស់ពួកគេខ្លាច។ អាកប្បកិរិយា គ្រប់គ្រងបែបនេះ ត្រូវបានធ្វើឡើងដើម្បីធ្វើឱ្យបុគ្គលម្នាក់ពឹងផ្អែកលើអ្នកបំពានរបស់ពួកគេ ដោយផ្តាច់ពួកគេចេញពី ការគាំទ្រផ្គត់ផ្គង់ កេងប្រវ័ញ្ច ដកហូតឯករាជភាព និងគ្រប់គ្រងអាកប្បកិរិយាប្រចាំថ្ងៃរបស់ពួកគេ។

## ការកេងប្រវ័ញ្ច និងការបំពានលើកុមារ

ការបំពានលើកុមាររួមបញ្ចូលអ្វីគ្រប់យ៉ាងដែលបុគ្គល អង្គការ ឬដំណើរការធ្វើ ឬខកខានក្នុងការធ្វើ ដែលធ្វើឱ្យគ្រោះថ្នាក់ដល់កុមារដោយផ្ទាល់ ឬដោយប្រយោល ឬធ្វើខូចខាតដល់ការអភិវឌ្ឍសុវត្ថិភាព និងសុខភាពនាពេលអនាគតរបស់ពួកគេ។

ការកេងប្រវ័ញ្ចលើកុមារគឺជាពាក្យទូលាយដែលត្រូវបានប្រើដើម្បីពិពណ៌នាអំពីការបំពានលើកុមារដែល ត្រូវបានបង្ខំ គ្រប់គ្រង បង្ខិតបង្ខំ ឬជួញដូរទៅក្នុងសកម្មភាពកេងប្រវ័ញ្ច។ នេះរួមបញ្ចូលទាសភាព សម័យទំនើប និងការជួញដូរកុមារ និងកុមារដែលត្រូវបានបង្ខំ ឬជ្រើសរើសឱ្យចូលរួមក្នុងជម្លោះ ប្រដាប់អាវុធ។

## ការកេងប្រវ័ញ្ច និងការបំពានលើកុមារអាចពាក់ព័ន្ធនឹងចំណុចមួយ ឬច្រើនដូចខាងក្រោម៖

### ក) ការបំពានរូបរាងកាយរបស់កុមារ

ការបំពានរូបរាងកាយរបស់កុមារ គឺជាការប្រើប្រាស់កម្លាំងដោយចេតនាដែលបណ្តាលឱ្យមាន គ្រោះថ្នាក់ដល់កុមារដោយចេតនា ឬដោយអចេតនា។ នេះអាចជា ឧទាហរណ៍ មានទម្រង់ជា ការទះ បុក ដាល់ អង្រួន ទាត់ វាយ ដុត ការរុញច្រាន ឬការចាប់ច្របាច់។ ការបំពានលើរូប រាងកាយអាចជាទង្វើតែម្តង ឬម្តងហើយម្តងទៀត។ ការបំពានលើរូបរាងកាយមិនតែងតែ បន្សល់ទុកស្នាម ឬរបួសដែលអាចមើលឃើញនោះទេ។

### ខ) ការបំពានផ្លូវអារម្មណ៍របស់កុមារ

ការបំពានផ្លូវអារម្មណ៍របស់កុមារ ពាក់ព័ន្ធនឹងការធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់ផ្លូវអារម្មណ៍ បញ្ញា ស្មារតី ឬផ្លូវចិត្តរបស់កុមារ។ ការបំពានផ្លូវអារម្មណ៍របស់កុមាររួមបញ្ចូលទាំងការប្រើ ពាក្យសំដី ឬធ្វើសកម្មភាពមិនសមរម្យ និងការធ្វើឱ្យអាម៉ាស់និងការមិនឱ្យតម្លៃចំពោះកុមារ ឬទម្លាប់នៃការខកខានក្នុងការផ្តល់ឱ្យកុមារនូវការថែទាំ ទាំងផ្នែកមិនមែនជារាងកាយ និង ទំនាក់ទំនងអារម្មណ៍ជាមួយគ្នា។ ការប្រព្រឹត្តបែបនេះមានលទ្ធភាពខ្ពស់ក្នុងការធ្វើឱ្យប៉ះពាល់ ដល់ការឱ្យតម្លៃខ្លួនឯង ឬសមត្ថភាពសង្គមរបស់កុមារ។ ឧទាហរណ៍រួមមានប៉ុន្តែមិនកំណត់

ត្រឹម ការគំរាមកំហែង ការគំហក/ការស្រែក ការហៅឈ្មោះដោយគំហក ការរិះគន់ឥតឈប់ឈរ និងការមើលងាយ។

## គ) ការមិនអើពើចំពោះកុមារ

ការមិនអើពើចំពោះកុមារ គឺជាការខកខានក្នុងការបំពេញតម្រូវការមូលដ្ឋានរបស់កុមារ។ ការមិនអើពើចំពោះកុមារជាការខកខានក្នុងការផ្តល់ឱ្យកុមារនូវ (នៅពេលដែលបុគ្គលម្នាក់អាចធ្វើបាន) ស្ថានភាពដែលត្រូវបានទទួលស្គាល់ជាវប្បធម៌ថាចាំបាច់សម្រាប់ការអភិវឌ្ឍរូបរាងកាយនិងផ្លូវអារម្មណ៍ និងសុខុមាលភាពរបស់កុមារ។ នេះរួមបញ្ចូលទាំងការខកខានក្នុងការផ្តល់អាហារគ្រប់គ្រាន់ សម្លៀកបំពាក់គ្រប់គ្រាន់ឬតាមរដូវកាលសមរម្យ និង/ឬទីជម្រក។

## ឃ) ការបំពានផ្លូវភេទកុមារ

ការបំពានផ្លូវភេទកុមារ គឺជាទម្រង់ណាមួយនៃសកម្មភាពផ្លូវភេទជាមួយកុមារ មិនថាកុមារដឹងឬមិនដឹងអំពីអ្វីដែលកំពុងកើតឡើងក៏ដោយ។ ការបំពានផ្លូវភេទកុមារ ត្រូវបានបង្ហាញដោយសកម្មភាពផ្លូវភេទរវាង កុមារ និងមនុស្សពេញវ័យឬកុមារផ្សេងទៀត ដែលតាមអាយុឬការអភិវឌ្ឍគឺស្ថិតនៅក្នុងទំនាក់ទំនងនៃការទទួលខុសត្រូវ ការទុកចិត្ត ឬអំណាច ហើយសកម្មភាពផ្លូវភេទនេះមានគោលបំណងដើម្បីផ្តល់ភាពរីករាយ ឬបំពេញតម្រូវការរបស់បុគ្គលម្ខាងទៀត។ ការបំពានផ្លូវភេទកុមារ រួមបញ្ចូលប៉ុន្តែមិនកំណត់ត្រឹម សកម្មភាពប៉ះពាល់ដូចជាការបំពានដោយការបញ្ចូល ការសម្រេចកាមខ្លួនឯង ការថើប ការស្ទាបអង្អែល និងការប៉ះពាល់ខាងក្រៅសម្លៀកបំពាក់ ការប្រើប្រាស់កុមារក្នុងការបម្រើផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទកុមារ និងការរៀបការទាំងវ័យក្មេង។ ការបំពានផ្លូវភេទកុមារ ក៏រួមបញ្ចូលផងដែរនូវសកម្មភាពដែលមិនប៉ះពាល់គ្នាដូចជាការញុះញង់ ឬការបង្ខិតបង្ខំកុមារឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទណាមួយ ការបង្ហាញកុមារទៅនឹងមាតិកាកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ ការប្រើប្រាស់កុមារក្នុងការផលិតរូបភាពនិងមាតិកាមិនសមរម្យ ឬការថតរូបភាពកេងប្រវ័ញ្ចផ្លូវភេទរបស់កុមារ។ ការបំពានផ្លូវភេទកុមារ អាចត្រូវបានប្រព្រឹត្តឡើងដោយមនុស្សគ្រប់រូប - បុរស និងស្ត្រីពេញវ័យ ក៏ដូចជាកុមារផ្សេងទៀត។

## ង) ការកេងប្រវ័ញ្ចផ្លូវភេទកុមារ

ការកេងប្រវ័ញ្ចផ្លូវភេទកុមារគឺជាទម្រង់មួយនៃការបំពានផ្លូវភេទកុមារ។ ការកេងប្រវ័ញ្ចផ្លូវភេទកើតឡើងនៅពេលដែលបុគ្គលម្នាក់ ឬក្រុមមួយទាញយកអត្ថប្រយោជន៍ពីអតុល្យភាពនៃអំណាចដើម្បីបង្ខិតបង្ខំ គ្រប់គ្រង ឬបោកបញ្ឆោតកុមារ ឬបុគ្គលវ័យក្មេងដែលមានអាយុក្រោម ១៨ ឆ្នាំ ទៅក្នុងសកម្មភាពផ្លូវភេទ - (ក) ជាថ្នូរនឹងអ្វីមួយដែលជនរងគ្រោះ/អ្នករស់រានមាន

ជីវិតត្រូវការ ឬចង់បាន និង/ឬ (ខ) សម្រាប់អត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬការតំឡើងឋានៈរបស់ជនល្មើស ឬអ្នកសម្របសម្រួល។ ជនរងគ្រោះ/អ្នករស់រានមានជីវិតអាចត្រូវបានកេងប្រវ័ញ្ចផ្លូវភេទ ទោះបីជាសកម្មភាពផ្លូវភេទហាក់ដូចជាមានការព្រមព្រៀងគ្នាក៏ដោយ ដោយសារកុមារត្រូវបានគេចាត់ទុកថាមិនមានសមត្ថភាពក្នុងការផ្តល់ការយល់ព្រមបានទេ។ ការកេងប្រវ័ញ្ចផ្លូវភេទកុមារ មិនមែនជារឿងដែលពាក់ព័ន្ធនឹងការប៉ះពាល់រូបរាងកាយគ្រប់ពេលឡើយ ឧទាហរណ៍ ការកេងប្រវ័ញ្ចផ្លូវភេទអាចកើតឡើងដោយការប្រើប្រាស់បច្ចេកវិទ្យា។ ការបំពានផ្លូវភេទកុមារក៏រួមមាន ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការជួញដូរមនុស្សផងដែរ។ បុគ្គលគ្រប់រូបអាចជាជនល្មើស នៃការកេងប្រវ័ញ្ចផ្លូវភេទកុមារដោយមិនគិតពីអាយុឬភេទរបស់ពួកគេឡើយ។ កុមារដែលត្រូវបាន/កំពុងត្រូវបានកេងប្រវ័ញ្ចក៏អាចត្រូវបានប្រើដោយជនល្មើសដើម្បី 'ស្វែងរក' ឬបង្ខំឱ្យកុមារដទៃ ចូលទៅក្នុងការកេងប្រវ័ញ្ចផងដែរ។

ច) **ពលកម្មកុមារ**

ពលកម្មកុមារ គឺជាការងារដែលធ្វើឱ្យកុមារបាត់បង់កុមារភាព សក្តានុពល និងកិត្តិយសរបស់ពួកគេ ហើយដែលធ្វើឱ្យប៉ះពាល់ដល់ការអភិវឌ្ឍផ្លូវកាយ និងផ្លូវចិត្ត។ ពលកម្មកុមារជាការងារដែល៖ ធ្វើឱ្យពួកគេមិនមានឱកាសទៅរៀន ធ្វើឱ្យពួកគេត្រូវឈប់ពីសាលាមុនពេលកំណត់ ឬតម្រូវឱ្យពួកគេព្យាយាមទៅរៀន ជាមួយនឹងការធ្វើការយូរម៉ោង និងធ្ងន់ហួសប្រមាណ។

ប្រសិនបើកុមារជាផ្នែកមួយនៃគម្រោងហ្វឹកហ្វឺនកូនជាងក្រោមច្បាប់របស់ប្រទេស ហើយមិនបានបំពេញលក្ខខណ្ឌណាមួយខាងលើនោះទេ អង្គការឃែរ នឹងមិនចាត់ទុកថាជាពលកម្មកុមារនោះទេ។ ទោះជាយ៉ាងណាក៏ដោយ អ្នកម៉ៅការ ឬអ្នកម៉ៅការបន្តណាមួយត្រូវជូនដំណឹងទៅអង្គការឃែរ អំពីឈ្មោះកូនជាងណាម្នាក់ដែលនឹងពាក់ព័ន្ធនឹងការងាររបស់យើងដោយផ្ទាល់ និងផ្តល់ការហេតុផលត្រឹមត្រូវជាលាយលក្ខណ៍អក្សរ អំពីការជួលបុគ្គលិករបស់ពួកគេស្របតាមច្បាប់ជាតិ។

## ការល្បួងលោម និងការល្បួងលោមតាមអនឡាញ

ការល្បួងលោម ជាទូទៅសំដៅទៅលើអាកប្បកិរិយាកេងប្រវ័ញ្ច ដែលប្រព្រឹត្តដោយជនល្មើស ដើម្បីបម្រុងទុក កុមារ ឬមនុស្សពេញវ័យដែលងាយរងគ្រោះសម្រាប់សកម្មភាពផ្លូវភេទនៅពេលក្រោយ។ ជានិច្ចកាល ការល្បួងលោមរួមបញ្ចូលទាំងការកសាងទំនុកចិត្តរបស់កុមារ និង/ឬអ្នកថែទាំពួកគេ ឬមនុស្សពេញវ័យដែលងាយរងគ្រោះ និងការគ្រប់គ្រងដោយបង្ខំ ដើម្បីអាចស្គាល់ពួកគេដើម្បីការបំពានផ្លូវភេទ។ ឧទាហរណ៍ ការល្បួងលោមរួមមានការផ្តល់ឱ្យ ឬការយកចិត្តទុកដាក់ដល់កុមារ ឬមនុស្ស

ពេញវ័យជាក់លាក់ ការផ្តល់អំណោយ ប្រាក់ គ្រឿងញៀន ឬគ្រឿងស្រវឹងដល់ពួកគេ ការជម្រុញអារម្មណ៍ផ្លូវភេទ ឬការបង្ហាញពួកគេទៅទស្សនៈផ្លូវភេទតាមរយៈការសន្ទនា ឬការបង្ហាញទៅមាតិកាអាសអាភាស ឬរូបភាពមិនសមរម្យ។

ការលួងលោមតាមអនឡាញ គឺជាសកម្មភាពផ្ញើសារអេឡិចត្រូនិក ឬការផ្ញើសារជាបន្តបន្ទាប់ ឬការចូលរួមក្នុងវេទិកាអនឡាញជាមួយនឹងខ្លឹមសារដែលអាចមានលក្ខណៈមិនសមរម្យ ដោយមានបំណងប្រព្រឹត្តការបំពានផ្លូវភេទ។ ដោយប្រើវិធីសាស្ត្រអនឡាញ (ឧបករណ៍ ប្រព័ន្ធបណ្តាញសង្គម វេទិកាអនឡាញ ។ល។) អ្នកបំពាននឹងបង្កើតទំនាក់ទំនង ទំនុកចិត្ត និងទំនាក់ទំនងផ្លូវអារម្មណ៍ជាមួយកុមារ ឬបុគ្គលពេញវ័យដែលងាយរងគ្រោះដោយមានបំណងគ្រប់គ្រង កេងប្រវ័ញ្ច និងបំពានពួកគេ ឬបង្ខំពួកគេឱ្យធ្វើសកម្មភាពបំពានផ្លូវភេទជាមួយមនុស្សម្នាក់ទៀត និង/ឬបង្ខំកុមារ ឬមនុស្សពេញវ័យដែលងាយរងគ្រោះឱ្យផ្ញើរូបភាពមិនសមរម្យ។ ជនល្មើសអាចគំរាមកំហែងក្នុងការបង្ហាញរូបភាពរបស់ជនរងគ្រោះ/អ្នករស់រានមានជីវិត និងប្រើអាកប្បកិរិយាបំភ័យ និងបង្ខិតបង្ខំ ដើម្បីគ្រប់គ្រងអ្នកដែលពួកគេកំពុងបំពាន។ កុមារ ឬមនុស្សពេញវ័យដែលងាយរងគ្រោះមួយចំនួនប្រហែលជាមិនអាចដឹងទេថាពួកគេត្រូវបានលួងលោម ហើយពួកគេប្រហែលជាគិតថាអាកប្បកិរិយាបែបនេះជារឿងធម្មតា ឬពួកគេមិនមានជម្រើសអ្វីនោះទេ។

ទាំងកុមារ និងមនុស្សពេញវ័យដែលងាយរងគ្រោះអាចជាជនរងគ្រោះ/អ្នករស់រានមានជីវិតពីការលួងលោម និងលួងលោមតាមអនឡាញ ដោយកុមារជាគោលដៅជាពិសេសតាមអនឡាញ។

## ជនរងគ្រោះ/អ្នករស់រានមានជីវិត

បុគ្គលដែលត្រូវបានគេបំពានក្នុងទម្រង់ណាមួយ រួមទាំងការកេងប្រវ័ញ្ច ការបៀតបៀនផ្លូវភេទ ការបំពានលើរូបរាងកាយនិងអារម្មណ៍ ការមិនអើពើ និងការបំពានកុមារ។ អង្គការឃែរ ទទួលស្គាល់ថាបុគ្គលនានាអាចជ្រើសរើសការប្រើពាក្យ "ជនរងគ្រោះ" ឬ "អ្នករស់រានមានជីវិត" ដូច្នេះពាក្យទាំងពីរត្រូវបានបញ្ចូលនៅក្នុងនិយមន័យ និងគោលនយោបាយការការពាររបស់ អង្គការឃែរ។

## អ្នកប្តឹង/អ្នករាយការណ៍

បុគ្គលដែលដាក់ពាក្យបណ្តឹង ឬរាយការណ៍ពីការព្រួយបារម្ភដែលពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការបំពាន (នេះអាច ឬមិនអាចជាបុគ្គលដែលរងផលប៉ះពាល់ ឬជនរងគ្រោះ/អ្នករស់រានមានជីវិត)។

## បុគ្គលជាកម្មវត្ថុនៃបណ្ដឹង

បុគ្គល (ឬក្រុមមនុស្ស) ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តទម្រង់ណាមួយនៃការបំពាន រួមទាំងការបៀតបៀន ការកេងប្រវ័ញ្ច ឬការបំពានផ្លូវភេទ ការបំពានលើរូបរាងកាយនិងផ្លូវអារម្មណ៍ ការធ្វេសប្រហែស ឬការបំពានកុមារ ឬប្រភេទផ្សេងទៀតនៃបទល្មើស។

## អ្នកស្ម័គ្រចិត្តសហគមន៍

បុគ្គលដែលស្ម័គ្រចិត្តធ្វើការក្នុងសហគមន៍ ដែលមាន អង្គការឃែរ ធ្វើកិច្ច ។

## និយោជិតដែលទទួលបានការលើកទឹកចិត្ត

បុគ្គលដែលទទួលបានការលើកទឹកចិត្ត (ហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ) ដើម្បីធ្វើកិច្ចការរបស់ អង្គការឃែរ ដែលមានលក្ខណៈបណ្ដោះអាសន្ន និងស្ម័គ្រចិត្ត។ ឧទាហរណ៍ និយោជិតដែលទទួលបានការលើកទឹកចិត្ត អាចជាបុគ្គលដែលមានស្ថានភាពជាជនភៀសខ្លួន ជនភៀសខ្លួនក្នុងស្រុក ជនមាតិភូមិនិវត្តន៍ ឬជាសមាជិកសហគមន៍ម្ចាស់ផ្ទះដែលទទួលបានការលើកទឹកចិត្ត ដែលកំពុងធ្វើការសម្រាប់ អង្គការឃែរ ជាថ្នូរនឹងការលើកទឹកចិត្ត។

## ភ្ញៀវ

សំដៅលើបុគ្គលដែលកំពុងមកទស្សនកិច្ចការិយាល័យ អង្គការឃែរ ឬកម្មវិធី រួមមានប៉ុន្តែមិនកម្រិតត្រឹមៈ តំណាងម្ចាស់ជំនួយ អ្នកសារព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយ អ្នកស្រាវជ្រាវ តារាល្បី សមាជិកគ្រួសារ។